កុមាររៀន
កុមារចេះ
ក ១ ២៣

# ខ្ញុំចូលចិត្តញ៉ាំ



កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា

រឿង ៖ **ខ្ញុំចូលចិត្តញ៉ាំ**
និពន្ធដោយ ៖ **ខន សុខឿន**
វិចិត្ររូបភាពដោយ ៖ **អែល ហ៊ុយណូ**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read
www.LetsReadAsia.org

ខ្ញុំចូលចិត្តញ៉ាំអាម៉ុកត្រី នៅផ្ទះយាយតា។



ខ្ញុំចូលចិត្តញ៉ាំសម្លកកូរ នៅផ្ទះអ៊ុំប្រុសអ៊ុំស្រី។



ខ្ញុំចូលចិត្តញុាំសម្លប្រហើរ
នៅផ្ទះពូមីង។



ខ្ញុំចូលចិត្តញ៉ាំសម្លម្ជូរគ្រឿង នៅផ្ទះបងស្រីជីដូនមួយ។



ខ្ញុំចូលចិត្តញ៉ាំប្រហុកគ្រឿង នៅផ្ទះបងប្រុសជីដូនមួយ។



ខ្ញុំចូលចិត្តញ៉ាំសម្លម្ជូរព្រលិត នៅផ្ទះរំដួល។



ខ្ញុំចូលចិត្តញ៉ាំទឹកគ្រឿង នៅផ្ទះណាវ៉ាត់។



ខ្ញុំចូលចិត្តញ៉ាំនំបញ្ចុកសម្លខ្មែរ
នៅផ្ទះបូផា។



ខ្ញុំចូលចិត្តញ៉ាំនំបញ្ចុកសម្លការី
នៅផ្ទះសុខា។



ខ្ញុំចូលចិត្តញ៉ាំអាម៉ុកត្រី សម្លកកូរ សម្លប្រហើរ សម្លម្ជូរគ្រឿង ប្រហុកគ្រឿង សម្លម្ជូរព្រលិត ទឹកគ្រឿង នំបញ្ចុកសម្លខ្មែរ និងនំបញ្ចុក សម្លការី។



ខ្ញុំចូលចិត្តញ៉ាំម្ហូបគ្រប់មុខ នៅពេលខ្ញុំនៅជាមួយមិត្តភក្តិរបស់ខ្ញុំ។



ខ្ញុំចូលចិត្តញ៉ាំម្ហូបគ្រប់មុខ នៅពេលខ្ញុំនៅជាមួយក្រុមគ្រួសាររបស់ខ្ញុំ។



# សំណួរ

១. តើតួអង្គនៅក្នុងរឿងនេះចូលចិត្តញ៉ាំ
អាម៉ុកត្រីនៅផ្ទះនរណា?

២. តើតួអង្គនៅក្នុងរឿនេះចូលចិត្តញ៉ាំអ្វី
នៅផ្ទះរំដួល?

៣. តើកូនដឹងទេថា ហេតុអ្វីបានជាតួអង្គ
នៅក្នុងរឿងនេះចូលចិត្តញ៉ាំអាហារ
ជាមួយក្រុមគ្រួសារ និងមិត្តភក្តិ?

៤. តើកូនចូលចិត្តញ៉ាំម្ហូបណាជាងគេ?
ហេតុអ្វី?

សិស្សថ្នាក់ទី១ ដែលកំពុងរៀននៅចុងឆ្នាំសិក្សា និង សិស្សថ្នាក់ទី២ ដែលកំពុងរៀននៅដើមឆ្នាំសិក្សា អាចអានសៀវភៅរឿងនេះ ដើម្បីជាការហ្វឹកហាត់អំណានបន្ថែម ដោយមិនចាំបាច់មានអ្នកដទៃជួយឡើយ។ ទោះយ៉ាងណា សិស្សក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើល និងនិយាយអំពីរូបភាពនៅក្នុងសៀវភៅរឿងនេះហើយអានពាក្យ និងតួអក្សរដែលពួកគេស្គាល់។

ដរាបណាសិស្សចាប់ផ្ដើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែល្អសម្រាប់ពួកគេ។



កម្មវិធីជាតិស្ដីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

បោះពុម្ពឆ្នាំ ២០២០